## យើងអាចជួយអ្នក

***អ្នកមានសិទ្ធិ ចំពោះការបំរើពីអ្នកបកប្រែ ។***

*ត្រូវកុំភ្លេចអានឃោសនាប័ណ្ណមានចំណងជើងថា សិទ្ធិរបស់អ្នកចំពោះការបំរើពីអ្នកបកប្រែ ព្រមទាំងឃោសនាប័ណ្ណកម្មវិធីផ្សេងៗទៀត ។ ទាំងអស់នេះសុទ្ធតែមានព័ត៏មានសំខាន់ៗ ។*

***បើសិនជាអ្នកមានបញ្ហាក្នុងការយល់ដឹងវា អ្នកកាន់សំណុំរឿងរបស់អ្នកអាចជួយអ្នកបាន ។***

DEPARTMENT OF
TRANSITIONAL
ASSISTANCE

*NCIB - Khmer (7/2010)*
*25-407-0710-05*

# អ្វីៗដែលអ្នក គ្មានសញ្ជាតិ ត្រូវដឹង

DEPARTMENT OF TRANSITIONAL ASSISTANCE dta

# អ្វីៗដែលអ្នកគ្មានសញ្ជាតិត្រូវដឹង

***កូនរបស់អ្នក អាចនឹងមានសិទ្ធិទទួលប្រាក់ និង/ឬ អត្ថប្រយោជន៍កម្មវិធីជំនួយអាហារមានជីវជាតិបន្ថែម (Supplemental Nutrition Assistance Program - SNAP)*** *សូម្បីតែបើអ្នកពុំអាចទទួលក៏ដោយ ។*

***ចូរកុំខ្លាចដាក់ពាក្យសុំអត្ថប្រយោជន៍សំរាប់ខ្លួនអ្នក ឬគ្រួសាររបស់អ្នក ។*** *ទោះបើអ្នកពុំមានសិទ្ធិទទួល ដោយព្រោះស្ថានភាពអន្តោប្រវេសន៍ក្តី* ***ក៏យើងនឹងមិនរាយការណ៍អ្នកទៅអាជ្ញាធរអន្តោប្រវេសន៍ឡើយ*** *លុះត្រាតែអ្នកផ្តល់ឲ្យយើងនូវបទបញ្ញត្តិផ្ទាល់ព្រ័ត្រនៃការនិរទេស ។*

*បើអ្នកមានអារម្មណ៍ថាអ្នកមិនអាចផ្តល់ព័ត៌មានឲ្យយើង អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ អ្នកនឹងពុំមានសិទ្ធិទទួលអត្ថប្រយោជន៍ឡើយ ។ សមាជិកគ្រួសាររបស់អ្នក ប្រហែលនៅអាចទទួលអត្ថប្រយោជន៍បាន ។ កាលណាអ្នកប្រាប់អ្នកកាន់សំណុំរឿងរបស់អ្នក ថាអ្នកមិនអាចផ្តល់ព័ត៌មាននេះឲ្យយើងទេ អ្នកកាន់សំណុំរឿងរបស់អ្នក នឹងឈប់សួរអ្នកអំពីស្ថានភាពរបស់អ្នកទៀត ។*

***ក៏ប៉ុន្តែ*** *អ្នកកាន់សំណុំរឿងរបស់អ្នក ត្រូវតែសួរសំណួរអ្នកផ្សេងៗទៀត ស្តីអំពីរូបអ្នក រួមទាំងទីកន្លែងអ្នករស់នៅ ប្រាក់ចំណូល ប្រាក់ឧបត្ថម្ភកូនរបស់អ្នកជាដើម ។ យើងត្រូវការព័ត៌មាននេះ ដើម្បីសំរេចសិទ្ធិទទួលអត្ថប្រយោជន៍ សំរាប់សមាជិកគ្រួសាររបស់អ្នក ។ ប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់អ្នកអាចនឹងបានរាប់ក្នុងការអនុម័តសិទ្ធិទទួល និងចំនួននៃអត្ថប្រយោជន៍សំរាប់គ្រួសាររបស់អ្នក ។*

*អ្នកមូលដ្ឋានជាអចិន្ត្រៃយ៍ពេញច្បាប់* (Legal Permanent Residents - LPR) *ខ្លះ ដែលដាក់ពាក្យសុំអត្ថប្រយោជន៍* SNAP *អាចនឹងត្រូវបានសួរអំពីអ្នកធានារបស់គេ ។ បើអ្នកជាមនុស្សក្នុងគ្រួសារដែលមានសមាជិកគ្មានសិទ្ធិទទួល នោះប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់អ្នកធានា អាចនឹងបានប្រើក្នុងការសំរេចសិទ្ធិទទួល* SNAP *និងចំនួនអត្ថប្រយោជន៍ ។ លើសពីនេះទៅទៀត អ្នកដែលទទួលប្រាក់មិនពិការ -* SSI *និងមនុស្សក្នុងគ្រួសារខ្លះជាមនុស្សចាស់ជរា អាចនឹងបន្តទទួលទៀត អាស្រ័យទៅលើការពិចារណាអ្នកធានា ។*

***ការចងចាំ :*** *បើអ្នកមិនប្រាប់យើងអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ អត្ថប្រយោជន៍ របស់អ្នកអាចនឹងទាបជាងពីធម្មតា ។*

*បើសិនជាអ្នកមានសំណួរ អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក ឬអំពីរបៀបទទួលអត្ថប្រយោជន៍ ប៉ះពាល់ជាយ៉ាងណាទៅលើសមត្ថភាពរបស់អ្នក ដើម្បីកែសំរួលស្ថានភាពរបស់អ្នក ឬបើមានសំណួរអ្វីផ្សេងទៀត អ្នកអាចទូរស័ព្ទទៅភ្នាក់ងារណាមួយដែលមានកត់នៅក្នុងឃោទាប័ណ្ណ* Noncitizens Resources *(ធនធានសំរាប់អ្នកគ្មានសញ្ជាតិ) ។*